# ការបង្កើនប្រាក់ចំណូលរបស់បងស្រី សំសាវេតក្នុងក្រុមជួយខ្លួនឯង/ក្រុមផលិត

**បងស្រីសំ សាវេត**អាយុ៣៨ឆ្នាំ រស់នៅភូមិក្រសាំង សង្កាត់ក្របីរៀល ក្រុងសៀមរាប មកពីគ្រួសារក្រីក្រមានប័ណ្ណ



សមធម៌ ២ ដែលពុំបានទទួលការសិក្សាខ្ពស់ទេគឺត្រឹមតែថ្នាក់ទី៤ថ្មីប៉ុណ្ណោះ សព្វថ្ងៃបងស្រី**សំ សាវេត** មានកូន២នាក់ស្រី១ ប្រុស១ ហើយគាត់បានរស់នៅជាមួយម្តាយក្មេកដែលមានដីផ្ទះមួយកន្លែងប្រក់សង្ក័សី គ្រួសារគាត់ពុំមានដីស្រែ ឬដីចំការអ្វីទេហើយគ្មានដើមទុនសម្រាប់ការប្រកបរបរប្រចាំថ្ងៃដែរពោលគឺពីមុនគាត់ជាកម្មករសំណង់ រីឯកូនតូចៗពេលខ្លះ ទុកឲ្យនៅជាមួយជីដូនមើលថែ។ ទោះបីការខិតខំជួយការងារគ្រួសារយ៉ាងណា ជីវភាពគាត់នៅតែលំបាកដដែលព្រោះគាត់នៅជាប់ជំពាក់បំណុលធនាគារដែលខ្ចីគេមកសាងសង់លំនៅដ្ឋានកាលពីមុន។ នៅដើមខែសីហា ឆ្នាំ២០១៨ ក្រុមការងារគម្រោងលើកកម្ពស់ប្រជាជនក្រីក្របានមកផ្សព្វផ្សាយ ពីការបង្កើតក្រុមសន្សំ (ក្រុមជួយខ្លួនឯង) និងបានបង្កើតក្រុមមានឈ្មោះក្រុមថា ក្រុមក្រសាំងជោគជ័យ គ្រួសារគាត់បានចូលរួមជាមួយនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៩។គម្រោងចាប់ផ្តើមដាក់សន្សំ ដោយដាក់ម្តង ៥,០០០រៀល មួយខែសន្សំពីរដង។ "មុនពេលចូលក្រុមសន្សំ ខ្ញុំពុំមានជំនាញបច្ចេកទេស ឬផែនការគ្រួសារលើការដាំដុះទេ ហើយគ្មានទុនច្រើនសម្រាប់ប្រកបរបរអ្វីដែរ ពោលគឺការរស់នៅភាគច្រើន ក្រោយពីរកចំណូលបាន គឺបានត្រឹមសងធនាគារ ហើយមានពេលខ្លះ ខ្ញុំពិបាកចិត្ត និងអស់សង្ឃឹម លើជីវិតរស់នៅប្រចាំថ្ងៃ មិនដឹងជារកអ្វីមកចិញ្ចឹមជីវិត។ នៅពេលក្រុមសន្សំបានចំនួន៦ខែក្រុមយើងមានប្រាក់ចំនួន ៨៤០,០០០រៀលខ្ញុំបានខ្ចីប្រាក់ក្រុមចំនួន ២០០,០០០រៀលយកទៅទិញសំភារៈ និងពូជសម្រាប់ដាំដំណាំដោយមានក្រុមការគម្រោងលាភ មកជួយផ្តល់បច្ចេកទេសខ្លះៗ ការដាំរបស់ខ្ញុំពុំទាន់ទទួលបានផលច្រើនទេ ដោយសារតែយើងសុំដីគេដាំដុះវាតូច ហើយបានផលតិច គឺបានត្រឹមតែហូបចុកនៅក្នុងគ្រួសារ ដោយមិនចាំបាច់ទិញគេ និងបានលក់តិចតួច។នៅដើមខែមករា ឆ្នាំ២០២០ គម្រោងបានទម្លាក់ទុនបន្ថែម ដល់ក្រុមចំនួន ៥,៦៩៥,២០០រៀល បងស្រី សំ សាវេត បានដាក់សំណើសុំខ្ចីទុនបន្ថែមសម្រាប់ពង្រីកការដាំបន្លែរបស់គាត់ឲ្យប្រសើរជាងមុនចំនួន ៤០០,០០០រៀល។



**ពី**មុនបងស្រី**សំ សាវេត**បានដាំបន្លែត្រឹមតែ៥០០ម៉ែត្រការេម្ចាស់ដីបានមើលឃើញពីគ្រួសារក្រីក្រ ហើយមានការខិតខំព្យាយាមក្នុងការដាំដុះបានលើកទឹកចិត្តឲ្យបងស្រី**សំ សាវេត**ដាំក្នុងដីរបស់គាត់បន្ថែមចំនួន៥,០០០ម៉ែត្រការេទៀត។ នៅថ្ងៃទី០៤ ខែមិនា ឆ្នាំ២០២០គម្រោងបានបង្កើតជាក្រុមផលិតឲ្យមានជារូបរាងឡើង បងស្រី **សំ សាវេត**បានចូលជាមួយក្រុមផលិតជាមួយគេផងដែរ ហើយបានទទួលការបណ្តុះបណ្តាល លើជំនាញបច្ចេកទេសដាំដុះពីមន្ទីរកសិកម្មរុក្ខាប្រមាញ់ និងនេសាទមានការជួយជ្រោមជ្រែងពីក្រុមការងារគម្រោងលាភ និងអង្គការដៃគូផងនោះ គាត់បានពង្រីកការដាំដុះរហូតដល់៥,៥០០ម៉ែត្រការេទៀត។ បងស្រី **សំ សាវេត**ចាប់ពីការពង្រីកការដាំដុះ លើផ្ទៃដីកាន់តែច្រើន

សួនកសិដ្ឋានរបស់គាត់កំពុងជះឥទ្ធិពលជាវិជ្ជមាន ទៅលើហិរញ្ញវត្ថុគ្រួសារ។ ដែលពីមុនមិនទាន់មានក្រុមជួយខ្លួនឯង គាត់អាចផលិតបន្លែក្នុងផ្ទៃដីត្រឹមតែ៥០០ម៉ែត្រការេ និងអាចរកចំណូលបានត្រឹមតែ២០០ទៅ២៥០ដុល្លារក្នុងមួយខែបានត្រឹមសងបំណុលគេតែពេលនេះ តាំងពីមានក្រុមជួយខ្លួនឯងបានផ្តល់ទុនបងស្រី**សំ សាវេត**បានរៀបចំផែនការអភិវឌ្ឍន៍គ្រួសារ គាត់បានពង្រីកការផលិតបន្លែក្នុងផ្ទៃដី



រហូតដល់ ៥,០០០ ម៉ែត្រការេ និងបង្កើនប្រាក់ចំណូលបានដល់ទៅ ៨០០ដុល្លារក្នុង១ខែ នៃរដូវដាំដុះ។ ប្រាក់ចំណូលនេះគាត់អាចរ៉ាប់រងរាល់ការចំណាយចាំបាច់របស់គ្រួសាគាត់សម្រាប់សងបំណុលផងការរៀនសូត្ររបស់កូនៗផង ហើយធានាថាពួកគេមានលុយសម្រាប់ការថែទាំសុខភា នៅពេលដែលពួកគេត្រូវការ និងដាក់សន្សំក្នុងក្រុម១ខែ១០,០០០ រៀល ជាទៀងទាត់ផងដែរ។

**ក្នុង**ក្រុមផលិត( ភូមិក្រសាំង )បានមើលឃើសមាជិក្រុមជាគ្រួសារគំរូនេះ ក្រុមបានលើកទឹកចិត្តឲ្យគាត់ធ្វើជាអនុប្រធានក្រុមផលិត។ ទៅថ្ងៃអនាគត គាត់មានផែនការចិញ្ចឹមសត្វបន្ថែម ព្រមទាំងពង្រីកការដាំបន្លែឲ្យធំជាងមុន ក្រុមគ្រួសារបងស្រី**សំ សាវេត**បានលើកឡើងថា ការចាប់ផ្តើមដំបូងគេគឺ ដោយសារតែគម្រោងលាភដែលមកដាស់គាត់ឲ្យក្រោក ឬងើបពីភាពក្រីក្រនេះ គាត់នឹងខិតខំចែករំលែកចំណេះដឹង បទពិសោធន៍ល្អនាដល់សមាជិក ក្នុងក្រុមនិងអ្នកជិតខាង ក្នុងភូមិលើការដាំដុះនេះឲ្យបានច្រើនដែលអាចធ្វើទៅបាន។